**Declassified to Public**
**06 September 2012**



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Chambres Extraordinaires au sein
des Tribunaux Cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**

**សំណុំរឿងព្រហ្មទណ្ឌ**
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**
**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 001/18-07-2007-ECCC-OCIJ**

# កំណត់ហេតុនៃការសួរចម្លើយ
# Written Record of Interview of Charged Person
# Procès-verbal d'interrogatoire

ឆ្នាំពីរពាន់ប្រាំពីរ ខែវិច្ឆិកា ថ្ងៃទីម្ភៃប្រាំបួន នៅវេលាម៉ោងប្រាំបួននិងដប់ប្រាំនាទី
យើង **យូ ប៊ុនឡេង** និង Marcel Lemonde ជាសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញ
ដោយមានលោក ហម ហ៊ែល និង លោក លី ច័ន្ទតុលា ជាក្រឡាបញ្ជីអមផង
បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤
បានឃើញវិធាន ៥៨ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ
ដោយមានវត្តមានរបស់ អ៊ុច ចាន់ណូរ៉ា និង តាន់ប៊ាង ដាវ័ណ្ណ ជាអ្នកបកប្រែនៃអង្គជំនុំជម្រះវិសាមញ្ញដែលបានស្បថរួចហើយ។

ជនត្រូវចោទដែលមានអត្តសញ្ញាណដូចខាងក្រោម បានចូលខ្លួននៅចំពោះមុខយើង:
ឈ្មោះ**កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ភេទ ប្រុស កើតថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ១៩៤២ នៅ ភូមិពៅវើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ សញ្ជាតិ ខ្មែរ របររកស៊ី គ្រូបង្រៀន។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

ឪពុកឈ្មោះ កាំង គី (ស្លាប់) ម្តាយឈ្មោះ មាស គឹមសៀវ (រស់) ប្រពន្ធឈ្មោះ ឈឹម សុផល (ស្លាប់) មានកូន ០៤ នាក់ ទីលំនៅនៅភូមិអូរទទឹម ឃុំតាសាញ ស្រុកសំឡូត ខេត្តបាត់ដំបង។

ត្រូវដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពី **បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** និង **ការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ សីហា ឆ្នាំ ១៩៤៩**

បទល្មើសដែលមានចែង និង ផ្តន្ទាទោស តាមមាត្រា ៥ មាត្រា ៦ មាត្រា ២៩ (ថ្មី) និង មាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

ច្បាប់ដើមនៃកំណត់ហេតុនេះ ត្រូវបានសរសេរជាភាសាខ្មែរ។

សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញ លោក Robert Petit និង អ្នកស្រី ជា លាង ដែលត្រូវបានជូនដំណឹងត្រឹមត្រូវរួចហើយអំពីការសួរចម្លើយនេះ នៅក្នុងលិខិតជូនដំណឹង ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ៖

- ☒ អ្នកស្រី ជា លាង ត្រូវបានតំណាងដោយលោក ពេជ្រ សម្បត្តិ ជំនួយការជាន់ខ្ពស់របស់សហព្រះរាជអាជ្ញា។
- ☒ លោក Robert Petit ត្រូវបានតំណាងដោយលោក Alex Bates, ជំនួយការជាន់ខ្ពស់របស់សហព្រះរាជអាជ្ញា។

លោកមេធាវី **ការ សាវុត្ថ** និង Francois Roux សហមេធាវីរបស់ជនត្រូវចោទត្រូវបានកោះអញ្ជើញនៅក្នុងដីកាកោះអញ្ជើញចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ និង មានលទ្ធភាពបានពិនិត្យសំណុំរឿងតាំងពីពេលនោះមក មានវត្តមានទាំងពីរនាក់។

**ការសួរចម្លើយ**

**សួរ-ឆ្លើយ:**

**សំនួររបស់លោកសហចៅក្រមស៊ើបអង្កេត** YBL: ចំពោះរចនាសម្ព័ន្ធអង្គការលេខដែលជនត្រូវចោទបានប្រគល់ឲ្យយើង សុំអ្នកឆ្លើយបញ្ជាក់អំពីរចនាសម្ព័ន្ធនៃការគ្រប់គ្រងនេះ?

**ឆ្លើយ:** អង្គការលេខនេះមាន២: ទី១ ជារចនាសម្ព័ន្ធមុនការចាប់ខ្លួន នុន ហ៊ុយ (លេខ១) និង ក្រោយការចាប់ខ្លួន (លេខ២)។ នៅក្នុងអង្គការលេខទាំង២ ឈ្មោះដែលជាអក្សរដុត គឺជាឈ្មោះដែលដូចគ្នានឹងអង្គការលេខដែលលោកសហ

ចៅក្រមស៊ើបអង្កេតបានប្រគល់ឲ្យខ្ញុំនៅថ្ងៃទី៣ ខែតុលា។  ការរៀបចំនេះ ចាប់ផ្តើមមានកំណើតតាំងពីពេលដែលខ្ញុំធ្វើជាប្រធានស២១ មកម្លេះ។ អង្គការលេខនេះ ត្រូវបានសម្រេចដោយថ្នាក់លើរបស់ខ្ញុំ សុនសេន។ ក្នុងអង្គការលេខលេខ១ គណៈកម្មាធិការនៃស២១ មានសមាជិក៣រូប។ តាមផ្នែករដ្ឋបាល ខ្ញុំជាប្រធានស២១។ តាមផ្នែកបក្សកុម្មុយនិស្តកម្ពុជា ខ្ញុំជាលេខានៃគណៈកម្មាធិការបក្សនៃមន្ទីរស២១។ ផ្នែករដ្ឋបាល មិត្ត ហ៊ី ជាអនុប្រធាន។ រីឯផ្នែកបក្សកុម្មុយនិស្តកម្ពុជាវិញ គាត់ជាអនុលេខានៃគណៈកម្មាធិការបក្សនៃមន្ទីរស២១។ ចំណែកឈ្មោះ នុន ហ៊ុយ ទាំងផ្នែករដ្ឋបាល និងបក្ស គាត់ជាសមាជិកនៃគណៈកម្មាធិការ។

**សំនួរ លោក YBL:** សុំលោកបញ្ជាក់អំពីអង្គភាពក្រោមបង្គាប់ និង ខ្សែសង្វាក់នៃការបញ្ជា?

**ឆ្លើយ:** អំពីការងាររបស់អ្នកសួរចម្លើយ ទាក់ទងនឹងអង្គការលេខលេខ១ (មុនពេលចាប់ខ្លួន នុន ហ៊ុយ) ការចាត់ចែងអ្នកទោសឲ្យទៅអ្នកសួរចម្លើយ និងប្រមូលសេចក្តីសារភាពពីអ្នកសួរចម្លើយដើម្បីប្រគល់មកឲ្យខ្ញុំ គឺជាភារកិច្ចរបស់មិត្តហ៊ីទាំងស្រុង ហើយភារកិច្ចនេះមានតាំងតែពីពេលដែលណាតជាប្រធានមកម្លេះ។ នៅពេលខ្ញុំត្រូវបានតែងតាំងជាប្រធាននៃស២១ ខ្ញុំនៅរក្សាស្ថានភាពនេះដដែល ប៉ុន្តែ ដោយ ហ៊ីធ្វើឲ្យបែកការណ៍សម្ងាត់ទាក់ទងនឹងចម្លើយសារភាពដែលឆ្លើយទាក់ទងនឹងឈ្មោះ សោ ភិម ហៅ យ៉ាន់ ទើបសុនសេន ដកមិត្តហ៊ីមិនឲ្យបំពេញកិច្ចការងារទាក់ទងនឹងការសួរចម្លើយមនុស្សសំខាន់ៗទៀតទេ។ ភារកិច្ចនេះ សុនសេន បានប្រគល់មកឲ្យខ្ញុំ ដើម្បីរក្សាការសម្ងាត់បានល្អ និង ចាប់ពីពេលនោះមក មិត្ត ប៉ុន ទទួលបន្ទុកសួរចម្លើយមនុស្សសំខាន់។ ជាទូទៅ សុនសេន ចាត់តាំងប៉ុនឲ្យធ្វើការងារនេះ ប៉ុន្តែ មានករណីមួយ គឺករណីរបស់ កុយ ធួន សុនសេន បានចាត់តាំងឲ្យខ្ញុំសួរចម្លើយដោយខ្លួនឯង ។ ការផ្លាស់ប្តូរបែបនេះ មាននៅពេលដែលខ្ញុំធ្វើជាប្រធានស២១ បានប្រហែលជា៥ទៅ៦ខែ។

ទាក់ទងនឹងជនដទៃទៀតដែលធ្វើការក្នុងអង្គភាពនៃអ្នកសួរចម្លើយ អ្នកខ្លះមកពីម១៣ (ម៉មណៃ ទិត ប៉ុន ណាន និង អុន) អ្នកផ្សេងទៀតមកពីកងពល ៧០៣ (ទុយ និង ប៊ូ ) និងមានមួយនាក់ទៀតមកពីអង្គភាពនៅភ្នំពេញ (ត្រូវ)។ ខ្ញុំបានចាត់តាំង ម៉ម ណៃជាជំនួយការផ្ទាល់របស់ខ្ញុំ។ ពីដំបូង គាត់ទទួលខុសត្រូវសង្ខេបចម្លើយសារភាព ប៉ុន្តែ សុនសេន បានសម្រេចលុបចោលការធ្វើបែបនេះ ពីព្រោះវាធ្វើឲ្យខាតពេល។ បន្ទាប់មក (ចុងឆ្នាំ ១៩៧៧) ម៉ម ណៃ ទទួលបន្ទុកសួរចម្លើយអ្នកទោសសង្គ្រាមវៀតណាម។ ទាក់ទងនឹងអ្នកសួរចម្លើយស្ត្រី ពួកគេ គឺជាប្រពន្ធរបស់កម្មាភិបាល។ ពួកគេ ចូលរួម ចាប់តាំងពីពេលដែលអ្នកសួរចម្លើយម្នាក់បានរំលោភនារីជនរងគ្រោះម្នាក់: គាត់បានដាក់ដំបងចូលទៅក្នុងទ្វារមាសរបស់អ្នកទោសស្ត្រីម្នាក់ (ដែលជាអតីតគ្រូរបស់ខ្ញុំ  ឈ្មោះ ឌឹម សារឿន)។ ខ្ញុំមិនចាំអំពីទោសដែលគេបានដាក់ចំពោះអ្នកសួរចម្លើយនោះទេ។

**សំនួរលោក ML:** នៅក្នុងអង្គការលេខដែលយើងបានបង្ហាញលោកកាលពីលើកមុន មានអ្នកសួរចម្លើយ ៣ ក្រុមៈ ក្រុមក្តៅ ក្រុមត្រជាក់ ក្រុមអង្គាម។ ហេតុអ្វីបានជាលោក មិនយកតាមការបែងចែកនេះនៅក្នុងអង្គការលេខរបស់លោក?

**ឆ្លើយ:** ខ្ញុំបញ្ជាក់ថាពិតជាមានវិធីសាស្ត្រសួរចម្លើយ៣មែន។ ប៉ុន្តែ មិនមែនខ្ញុំជាអ្នកសម្រេចបែងចែកអ្នកសួរចម្លើយជា៣ក្រុមនោះទេ។ ខ្ញុំ មិនបានដឹងអំពីការរៀបចំនេះទេ ដែលប្រហែលអាចកើតមានតាំងពីសម័យណាតមកម្លេះ។ វិធីសាស្ត្រសួរចម្លើយនេះខ្ញុំធ្លាប់បានខទ្មេសនាមទៅអ្នកសួរចម្លើយដទៃទៀតមែន។ ខ្ញុំមិនបានបែងចែកជា៣ក្រុមទេ មានន័យថា អ្នកសួរចម្លើយ អាចធ្វើតាមវិធីសាស្ត្រនីមួយៗ តាមប្រភេទនៃអ្នកទោស។

**សំនួរលោក ML:** សុំលោកបង្ហាញប្រាប់យើងអំពីព្រៃស?

**ឆ្លើយ:** ព្រៃស ជាផ្នែកមួយនៃស២១។ វា មិនមែនជាកន្លែងសួរចម្លើយ ឃុំខ្លួន ឬ សម្លាប់នោះទេ។ វា ជាកន្លែងបង្កបង្កើនផល និង ការអប់រំកែប្រែ។ អ្នកដែលត្រូវបញ្ជូនទៅទីនោះ មិនមែនជាអ្នកទោសដែលត្រូវបានចោទប្រកាន់នោះទេ ប៉ុន្តែ ជាអ្នកដែលមានបញ្ហាវិន័យនៅក្នុងអង្គភាពរបស់គេនៅភ្នំពេញ។ អ្នកនៅទីនោះ មិនមានស្ថានភាពខុសពីអ្នកដែលធ្វើការនៅក្នុងសហករណ៍នោះទេ។ មនុស្សម្នាក់ មិនអាចធ្វើចរាចរដោយសេរីដោយគ្មានលិខិតអនុញ្ញាតនោះទេ។ អ្នកនៅទីនោះ រួមទាំងខ្ញុំផង គឺក៏ដូចគ្នាដែរ។ ប៉ុន្តែ ពួកគេមិនមែនត្រូវឃុំឃាំងនៅក្នុងគុកនោះទេ។

**សំនួរលោក YBL:** តើលោកអាចប្រាប់យើងអំពីកងពិសេស និង បញ្ជាក់ថាតើមានអង្គភាពដែលរ៉ាប់រងការងារនៅជើងឯកដែរឬទេ?

**ឆ្លើយ:** ខ្ញុំគិតថាមានអង្គភាពអចិន្ត្រៃយ៍មួយនៅជើងឯក ពីព្រោះ ត្រូវមានមនុស្សជីករណ្ដៅ ប៉ុន្តែ ខ្ញុំមិនដឹងច្បាស់ទេ។ គឺប្រហែលជាអ្នកដែលមកពីកងពិសេស ដែលអាចទៅធ្វើអន្តរាគមន៍បានគ្រប់ទីកន្លែង។

**សំនួរលោក YBL:** លោកបានលើកឡើងតែសមាជិក២ឬ៣នាក់នៃអង្គភាពកងការពារ និង កងពិសេសតែប៉ុណ្ណោះ។ តើនៅក្នុងអង្គភាពនិមួយៗ មានមនុស្សប៉ុន្មាននាក់?

**ឆ្លើយ:** កងពិសេស មានមនុស្ស ប្រហាក់ប្រហែលនឹងកងអនុសេនាតូច (ប្រហែល៣០នាក់) រីឯ កងការពារ មានមនុស្ស ប្រហាក់ប្រហែលនឹងអនុសេនាធំ (ប្រហែលជាជាង១០០នាក់)។ ខ្ញុំដាក់នៅក្នុងអង្គការលេខតែឈ្មោះមនុស្សដែលខ្ញុំនៅចាំតែប៉ុណ្ណោះ។

**សំនួរលោក YBL:** ទាក់ទងនឹងអង្គការលេខទី២ (ក្រោយពេលចាប់នុន ហ៊ុយ) តើមានការប្រែប្រួលអ្វីខ្លះដែលសំខាន់?

**ឆ្លើយ:** ចំនុចទី១ គឺការប្តូរមិត្តផលជំនួស នុនហ៊ុយ និង ការប្តូរឈ្មោះ ប៉េង ជំនួសមិត្ត ផល។ ចំនុចទី២ មិត្តហ៊ទទួលភារៈនៅភ្នំពេញលើគ្រប់ផ្នែក ទាំងការសួរចម្លើយ ទាំងការអានឯកសារ គឺអ្វីៗ ហ៊ជាអ្នកទទួលបន្ទុក មុននឹងបញ្ជូនមកខ្ញុំ។ ចំនុចទី៣ ខ្ញុំបានដកតួនាទីជាជំនួយការខ្ញុំពីហ៊ ព្រោះ នួនជា ជាអ្នកសម្រេចក្រោយពេលចាប់ខ្លួននុនហ៊ុយ។

**សំនួរលោក YBL:** លោកបានឆ្លើយថាដកការងារសំខាន់ពីមិត្ត ហ៊ នៅឆ្នាំ ១៩៧៦ ប៉ុន្តែ នៅពាក់កណ្ដាលឆមាសទី២នៃឆ្នាំ១៩៧៨នេះ លោកបានបញ្ជាក់ថា ហ៊ទទួលបន្ទុកកិច្ចការងារទាំងស្រុង។ សុំលោកបញ្ជាក់អំពីមូលហេតុ?



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa, Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

**ឆ្លើយ:** មូលហេតុទី១ ដោយសារការសម្លាប់កាលពីឆ្នាំ ១៩៧៦ មានអត្ថន័យធំធេងណាស់ លុះមកដល់ឆ្នាំ ១៩៧៨ ការសម្លាប់ដដែលនេះ លែងមានអត្ថន័យដូចមុនទៀតហើយ ព្រោះមនុស្សសំខាន់ៗខ្លះ ត្រូវបាននាំមកស២១រួចហើយ។ ម៉្យាងទៀត មានការប្ដូរមេដឹកនាំ គឺនួនជា ជាអ្នកចុះផ្ទាល់ និង ម៉្យាងទៀត ខ្ញុំចង់ប្រគល់ភារកិច្ចនេះ ទៅអ្នកដទៃ ពីព្រោះ ខ្ញុំចង់ដកខ្លួនចេញ។ ហើយ ហ៊ី ក៏មិនហ៊ានធ្វើឲ្យបែកការណ៍ទៀតដែរ ពីព្រោះគាត់មានការភ័យខ្លាច។

**សំនួរលោកជំនួយការសហព្រះរាជអាជ្ញា ពេជ្រសម្បត្តិ:** តើ នុនហ៊ុយ មានឈ្មោះផ្សេងទៀតដែរឬទេ?

**ឆ្លើយ:** គាត់មានឈ្មោះ ហ៊ុយស្រែ និង ហ៊ុយខ្ពស់។

**សំនួរលោកជំនួយការសហព្រះរាជអាជ្ញា ពេជ្រសម្បត្តិ:** ជនត្រូវចោទបានពន្យល់ថាខ្លួនបានទទួលបញ្ជាឲ្យសួរកុយធួន ដោយខ្លួនឯង និង មិនឲ្យប្រើទារុណកម្មទេ: តើអ្នកណាបញ្ជាឲ្យសម្លាប់គាត់ តើនរណាជាអ្នកសម្លាប់ និង តើការសម្លាប់នេះ ធ្វើឡើងនៅទីណា (នៅស២១ ឬ ជើងឯក)?

**ឆ្លើយ:** គឺសុនសេនដែលជាអ្នកសម្រេចចាប់ខ្លួន សម្រេចផ្ដល់ការសួរចម្លើយដំបូងមកឲ្យខ្ញុំ និងបន្ទាប់មកទៅឲ្យប៉ុន និង សម្រេចបញ្ចប់ការសួរចម្លើយ និង ការបញ្ជូនកុយធួនទៅសម្លាប់។ ខ្ញុំបានប្រគល់កុយធួនទៅឲ្យហ៊ី ប៉ុន្តែ ខ្ញុំមិនដឹងអ្វីដែលកើតឡើងនាពេលបន្ទាប់នោះទេ។ ហ៊ី ជាអ្នកទទួលបន្ទុកសម្លាប់។ ទាក់ទងនឹងទីកន្លែង ដូចដែលខ្ញុំបានពន្យល់កាលពីលើកមុន គេ បានធ្វើជាដំបូងនៅស២១ និង នាពេលក្រោយមក នៅជើងឯក។ ប៉ុន្តែ ចំពោះមនុស្សសំខាន់មួយចំនួន ការសម្លាប់នៅបន្តធ្វើនៅស២១។ ឧទាហរណ៍ ជនបរទេសបស្ចិមទាំង៤នាក់ដែលត្រូវបានសម្លាប់ និង ដុតកំទេចតាមបញ្ជារបស់នួនជា គឺត្រូវបានធ្វើឡើងនៅកែងផ្លូវម៉ៅសេទុង និងផ្លូវ ១៦៣។ នាពេលនោះ មានត្រពាំងមួយនៅទីនោះ ហើយ គឺនៅទីនោះហើយ ដែល វ៉ន វ៉េត ឆាយគីមហ៊្វ័រ និង ណាត ត្រូវបានសម្លាប់។

**សំនួរលោកជំនួយការសហព្រះរាជអាជ្ញា ពេជ្រសម្បត្តិ:** ជនត្រូវចោទបានប្រកាសថាគាត់បានបង្រៀនវិធីសាស្ត្រនៃការសួរចម្លើយ។ ជាក់ស្ដែង តើមានភាពខុសគ្នាយ៉ាងម៉េចរវាងវិធីសាស្ត្ររបៀបក្ដៅ ត្រជាក់ និង អង្គាម?

**ឆ្លើយ:** វិធីសាស្ត្រត្រជាក់ គឺជាវិធីដែលមិនមានការប្រើទារុណកម្ម និង ការជេរស្ដីទេ ប៉ុន្តែ ជាការប្រើការបញ្ចុះបញ្ចូលឃោសនា។ ឧទាហរណ៍ ពេលខ្ញុំសួរកុយ ធួន ខ្ញុំរង់ចាំ២ ឬ៣ម៉ោងមុននឹងសួរគាត់។ ខ្ញុំ ហៅគាត់បង។ ខ្ញុំសុំគាត់ឲ្យសរសេរចម្លើយសារភាពដើម្បីខ្ញុំដាក់ជូនអង្គការ។ ខ្ញុំបានទុកពេលឲ្យគាត់សរសេរ ហើយឲ្យមនុស្ស២នាក់នៅមើលគាត់ដើម្បីជៀសវាងគាត់ធ្វើអត្តឃាត។ បន្ទាប់ពីបានសរសេរកន្លះទំព័រ គាត់ចាប់ផ្ដើមខឹង ហើយបានហែកក្រដាសនិងកាច់វ៉ែនតាគាត់ចោល។ ខ្ញុំបានទុកឲ្យគាត់ស្ងប់អារម្មណ៍សិន ហើយ បន្ទាប់ពីការជជែកពិភាក្សាជាមួយគាត់ គាត់បានយល់ព្រមសរសេរចម្លើយសារភាពបន្តទៀត។ មេរបស់ខ្ញុំ បានតាមដានរឿងនេះតាមទូរស័ព្ទ ជាប្រចាំ។ នេះជាវិធីសាស្ត្រត្រជាក់។

វិធីសាស្ត្រក្ដៅ មានការជេរស្ដី ការវាយដំ និង ការធ្វើទារុណកម្មផ្សេងទៀតដែលបទបញ្ជាអនុញ្ញាតឲ្យធ្វើ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

ចំពោះវិធីសាស្ត្រអង្គាមវិញ គឺជាការពន្យល់លួងលោមដើម្បីបង្កើតភាពទុកចិត្តគ្នា និង បន្ទាប់មកជំរុញសួរ ដោយឱ្យគាត់សរសេរ។ ទារុណកម្ម ត្រូវបានប្រើផងដែរ ប៉ុន្តែ កម្រណាស់។ គេប្រើពាក្យអង្គាម ដោយសារតែវាត្រូវការពេលយូរ។

**និទ្ទេសរបស់សហចៅក្រមស៊ើបអង្កេត:** យើង ដាក់ ជាឧបសម្ព័ន្ធនៃកំណត់ហេតុនេះនូវអង្គការលេខទាំងពីរដែលមេធាវីរបស់ជនត្រូវចោទបានប្រគល់មកឱ្យយើង តាមលិខិតចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៧។

**ផ្អាកការធ្វើកំណត់ហេតុនៃការសួរចម្លើយ នៅវេលាម៉ោងដប់ពីរនិងម្ភៃនាទីគត់ ។**

**នៅវេលាម៉ោងដប់បួននិងដប់នាទីល្ងាចនៃថ្ងៃដដែល យើងចាប់ផ្តើមបន្តការសួរចម្លើយតទៅទៀត។**

**សំនួរលោក YBL:** នៅក្នុងអង្គការលេខទី១និងទី២ ផ្នែកឯកសារ មានឈ្មោះធី។ តើធីនេះ មានឈ្មោះពេញយ៉ាងដូចម្តេច?

**ឆ្លើយ:** មុនឆ្នាំ១៩៧៩ ខ្ញុំស្គាល់តែឈ្មោះធីនេះតែប៉ុណ្ណោះ។ ប៉ុន្តែ នៅពេលដែលខ្ញុំជាប់ឃុំនៅទីនេះ ខ្ញុំបានមើលខ្សែភាពយន្តរបស់រិទ្ធី ប៉ាន ដែលមានចំណងជើងថា ស២១ ទើបខ្ញុំដឹងថាគាត់មានឈ្មោះសួស ធី ហើយខ្ញុំស្គាល់ច្បាស់ថាសួស ធីនេះ ជាមនុស្សតែមួយដែលធ្លាប់ជាកូនចៅខ្ញុំឈ្មោះធីនោះឯង។

**សំនួរលោក YBL:** តើធីនេះ ធ្វើការងារអ្វីខ្លះ?

**ឆ្លើយ:** គាត់រៀបចំសៀវភៅបញ្ជី ដូចជាឈ្មោះអ្នកទោស ដែលស្រដៀងទៅនឹងអ្វីដែលលោកចៅក្រមបានបង្ហាញខ្ញុំ: គឺឯកសារ TSL 1865 និង TSL 1866។ បញ្ជីទាំងនេះ ត្រូវបានរៀបចំឡើងជាទៀងទាត់ និង ត្រូវមានចំណារផង។ ដើម្បីពន្យល់លោកចៅក្រមអំពីលក្ខណៈរបស់វា ខ្ញុំបានសរសេរកំណត់សម្គាល់២ ដែលមានចំណងជើងថា " សេចក្តីបញ្ជាក់លើបញ្ជី TSL 1865 (លេខ១) និង សេចក្តីបញ្ជាក់លើបញ្ជី TSL 1866 (លេខ២) " ដែលខ្ញុំសុំប្រគល់ជូនលោកចៅក្រម។

**និទ្ទេសរបស់សហចៅក្រមស៊ើបអង្កេត:** យើង ដាក់ជាឧបសម្ព័ន្ធនៃកំណត់ហេតុនេះនូវសេចក្តីបញ្ជាក់ទាំងពីរ (លេខ១ និង លេខ២) ដែលជនត្រូវចោទបានប្រគល់មកឱ្យយើង។

**ឆ្លើយ:** ខ្ញុំបានចារដោយខ្លួនខ្ញុំផ្ទាល់លើសៀវភៅបញ្ជីតែមួយដងគត់ គឺនៅពេលដែលហ៊ឺអវត្តមាន (គឺឯកសារ TSL 1865)។ ឯកសារ TSL 1866 ត្រូវបានចារដោយ ហ៊ឺ។ មានមួយដងទៀត ខ្ញុំបានធ្វើចំណារលើបញ្ជីអ្នកទោស ក្នុងក្រដាសពីរដាច់ពីគ្នា ប៉ុន្តែ វាមិនស្ថិតនៅក្នុងឯកសារដែលលោកចៅក្រមបង្ហាញខ្ញុំនោះទេ។ ទាក់ទងនឹងឯកសារដទៃទៀតដែលលោកចៅក្រមបានបង្ហាញខ្ញុំ ខ្ញុំសុំប្រគល់កំណត់សំគាល់២ទៀតដែលខ្ញុំបានសរសេរ។ ក្នុងកំណត់សំគាល់ទី១

(មានចំណងជើងថា ៉ សេចក្តីសារភាព ៉ ) (លេខ ៣) ខ្ញុំធ្វើការពន្យល់ឡើងវិញអំពីអ្វីដែលខ្ញុំបាននិយាយនៅក្នុងការសួរចម្លើយថ្ងៃទី២ ខែតុលា ឆ្នាំ២០០៧ ទាក់ទងនឹងឯកសារ DC-Cam 0000១៩០៣។ ខ្ញុំទទួលស្គាល់ថាខ្ញុំបានសរសេរលិខិតនោះ (ក៤) ហើយ ខ្ញុំពន្យល់ក្នុងកំណត់សម្គាល់របស់ខ្ញុំអំពីទំនាក់ទំនងជាមួយនឹងឯកសារដទៃទៀតដែលលោកចៅក្រមបានបង្ហាញខ្ញុំ ហើយ ដែលខ្ញុំហៅថា ក១ ក២ ក៣។ នៅក្នុងកំណត់សម្គាល់ទី២ ដែលខ្ញុំសុំប្រគល់ជូនលោកចៅក្រម (មានចំណងជើងថា សេចក្តីបញ្ជាក់លើឯកសារ ក១ ដល់ ក៤) (លេខ ៤) ខ្ញុំធ្វើការពន្យល់អំពីចំនុចលម្អិត។

**និទ្ទេសរបស់សហចៅក្រមស៊ើបអង្កេត:** យើង ដាក់ជាឧបសម្ព័ន្ធនៃកំណត់ហេតុនេះនូវកំណត់សម្គាល់ទាំងពីរ (លេខ ៣ និង លេខ ៤) ដែលជនត្រូវចោទបានប្រគល់មកឲ្យយើង។

**ឆ្លើយ:** ខ្ញុំនឹងធ្វើការពន្យល់បញ្ជាក់អំពីឯកសារទាំងនេះ នៅក្នុងការសួរចម្លើយលើកក្រោយ។

☒ យើងបានជូនដំណឹងដល់ជនត្រូវចោទ មេធាវីរបស់ជនត្រូវចោទ និង សហព្រះរាជអាជ្ញា អំពីការសួរចម្លើយលើកក្រោយដែលនឹងធ្វើនៅថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ ២០០៧ ម៉ោង ៩ព្រឹក។

☒ ឯកសារច្បាប់ដើមនៃការថតរូបភាពនិងសម្លេង ត្រូវបានបិទស្លាកបោះត្រានៅចំពោះមុខជនត្រូវចោទនេះ និង មេធាវីរបស់ជននេះ និង ត្រូវបានចុះហត្ថលេខាដោយ យើង ក្រឡាបញ្ជី សហព្រះរាជអាជ្ញា ជនត្រូវចោទ និង មេធាវីរបស់ជននេះ។

☒ ឯកសារច្បាប់ដើមមួយច្បាប់នៃការថតរូបភាពនិងសម្លេង ត្រូវបានប្រគល់ឲ្យជនត្រូវចោទនេះ។

នៅវេលាម៉ោងដប់ប្រាំមួយ និងសែសិបបីនាទីល្ងាច យើងបានឲ្យក្រឡាបញ្ជីអានខ្លាំងៗនូវកំណត់ហេតុសួរចម្លើយរបស់ជនត្រូវចោទនេះ ទៅតាមអ្វីដែលបានកត់ត្រា។

☒ អានឲ្យស្តាប់ហើយ ជនត្រូវចោទ មិនមានជំទាស់អ្វីទេ ហើយ សុខចិត្តចុះហត្ថលេខា។

| ជនត្រូវចោទ | មេធាវីជនត្រូវចោទ | សហព្រះរាជអាជ្ញា | អ្នកបកប្រែ | ក្រឡាបញ្ជី | សហចៅក្រមស៊ើបអង្កេត |
|---|---|---|---|---|---|
| Charged person<br>Personne mise en examen | Lawyer of Charged person<br>Avocat de la Personne mise en examen | C0-Prosecutors<br>Co-procureurs | Interpreter<br>Interprète | Greffiers | Co-Investigating Judges<br>Co-juges d'instruction |



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

**សូមគោរពចូលមក**

**លោក យូ ប៊ុនឡេង និង លោក** Marcel Lemonde

**សហចៅក្រមស៊ើបអង្កេត**

<u>**សំណុំរឿងលេខ** ៖ ០០១/១៨-០៧-២០០៧</u>

<u>**កម្មវត្ថុ** ៖ ការដាក់អង្គការលេខចំនួនពីរដែលបានរៀបចំឡើងដោយកូនក្តីរបស់យើងខ្ញុំ</u>

យើងខ្ញុំមេធាវី **ការ សាវុត្ថ** និង មេធាវី François Roux ការពារក្តីឱលោក **កាំង ហ្គេកអ៊ាវ** មានកិត្តិយសសូមប្រគល់ជូនលោកសហចៅក្រមស៊ើបអង្កេតទាំងពីរ នូវអង្គការលេខចំនួនពីរដែលបានរៀបចំឡើងដោយកូនក្តីរបស់យើងខ្ញុំ ដូចដែលបានតម្រូវនៅក្នុងសវនាការ កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ២០០៧។ អង្គការលេខទាំងនេះបង្ហាញនូវឈ្មោះ និងតួនាទីរបស់បុគ្គលិកនៅមន្ទីរ ស២១ ដែលកូនក្តីយើងខ្ញុំធ្លាប់ស្គាល់ និងអាចនៅចងចាំបានមកដល់សព្វថ្ងៃនេះ។

សូមលោកសហចៅក្រមទាំងពីរទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៧-១១-២០០៧

មេធាវី **ការ សាវុត្ថ**

មេធាវី François Roux

<u>ចម្លងជូន</u>៖

លោកស្រី ជា លាង

លោក Robert PETIT

សហព្រះរាជអាជ្ញា

<u>Comité du Bureau de S21</u> : Duch (*secrétaire*), Hor (*adjoint de Duch*) et Huy (*membre du Comité*) avant l'arrestation de Nun Huy *(dans la IIème moitié de 1978)*

(<u>គណៈកម្មាធិការមន្ទីរ ស២១</u>: ឌុច(*លេខាធិការ*) ហ៊ (អនុរបស់ឌុច) និងហ៊ុយ (សមាជិកគណៈកម្មាធិការ) មុនការចាប់ខ្លួនរបស់នុន ហ៊ុយ (នៅពាក់កណ្ដាលទី២នៃឆ្នាំ១៩៧៨)




E3/17

00154229

Comité du Bureau de S21 : Duch (*secrétaire*), Hor (*adjoint de Duch*) et Phal (*membre du Comité*) après l'arrestation de Nun Huy *(dans la IIème moitié de 1978)*
(គណៈកម្មាធិការមន្ទីរ ស២១: ឌុច(*លេខាធិការ*) ហ៊ (អនុរបស់ឌុច) និងផល (សមាជិកគណៈកម្មាធិការ) ក្រោយការចាប់ខ្លួនរបស់ហ៊ុយ (នៅពាក់កណ្ដាលទី២នៃឆ្នាំ១៩៧៨)

២

**Duch (ឌុច)**
**Président du Bureau de S21**
**[ប្រធានមន្ទីរស២១]**
*Education annuelle politique*
*(ការអប់រំនយោបាយប្រចាំឆ្នាំ)*

*Confessions*
*(ចម្លើយសារភាព)*

***Secteur Phnom Penh (ផ្នែកភ្នំពេញ)***
**Hor (ហ៊)**
*Administration (រដ្ឋបាល)*
*Education mensuelle (ការអប់រំប្រចាំខែ)*

***Secteur Prey Sâ (ផ្នែកព្រៃស)***
**Phal (ផល)**
*Rééducation (អប់រំ (កែប្រែ))*
*Production du riz (ធ្វើស្រែ)*
*Plantation de légumes (ដាំបន្លែ)*

***Unités des interrogateurs (អង្គភាពសួរចម្លើយ)***

***Hommes (បុរស)***
*Prisonniers importants :* **Pon** (*អ្នកទោសសំខាន់ៗ :* ប៉ុន),
*Prisonniers vietnamiens :* **Mam Nai** alias **Chan** et Chan *(interprète de Mam Nai)*, (*អ្នកទោសជនជាតិវៀតណាម :* ម៉ម ណៃ ហៅ ចាន់ និងចាន់ *(អ្នកបកប្រែភាសារបស់ម៉ម ណៃ)*),
Tuy(ទុយ), Trov(ត្រូវ) , **Bou**(ប៊ូ),
**Tith**(ទិត), Nan (ណាន), On(អុន)

***Femmes (ស្ត្រី)***
Mot (femme de Hor)
(ម៉ុត(ប្រពន្ធរបស់ហ៊)),
Ny (f. de Pon)
(នី (ប្រពន្ធរបស់ប៉ុន)),
Ran (f. de Trov)
(រ៉ន (ប្រពន្ធរបស់ត្រូវ))

***Unités militaires (អង្គភាពយោធា)***
**Peng (ប៉េង)**

***Garde de détention (កងការពារ)***
- **Peng (ប៉េង)**
- **Him Huy (ហ៊ឹម ហ៊ុយ)**
- Van (វ៉ាន់)

***Force Spéciale (កងពិសេស)***
- **Him Huy (ហ៊ឹម ហ៊ុយ)**
- Sry (ស្រី)
- Poy (ប៉ូយ)

***Unités annexes (អង្គភាពផ្សេងៗ)***
4 *Messagers/ gardes du corps (និរសា/អង្គរក្ស ៤នាក់)*
[3 messagers de Duch (និរសារបស់ឌុច៣នាក់): *Téléphone* (Phorn) *(ទូរស័ព្ទ* (ភន)*), Dactylo* (Than et Chhen) (*អង្គុលីលេខ* (ថាន់ និងឆេន)), 1 messager de Hor (Tha) (និរសារបស់ហ៊ម្នាក់ (ថា)]
*Administration et Personnel (រដ្ឋបាល និងបុគ្គលិក)*
*Economie (Elevage et plantation) (សេដ្ឋកិច្ច (ចិញ្ចឹមសត្វ និងដាំបន្លែ))*
*Logistique* (Than) (*ផ្នែកភស្តុភារ* (ថន))
[*Cuisine des prisonniers / cuisine du personnel* (Mom, femme de Chan)] [*ចុងភៅសម្រាប់អ្នកទោស - ចុងភៅសម្រាប់បុគ្គលិក* (ម៉ុម ប្រពន្ធរបស់ចាន់) ]
*Documentation* (**Thy**) (*ផ្នែកឯកសារ* (ធី))
*Dactylo* (Huoy) (*អង្គុលីលេខ* (ហួយ))
*Téléphone* (Phéng) (*ទូរស័ព្ទ* (ផេង))
*Médicaments traditionnels (ថ្នាំបុរាណ)*
*Infirmiers (គិលានុបដ្ឋាក)*
*Photographes* (Sreang, Song) (*អ្នកថតរូប* (ស្រ៊ាង សុង))

E3/17

០០១៥៤២២៩

1

# សេចក្តីបញ្ជាក់ លើបញ្ជី "32" TSL 1865

ចំណារលើបញ្ជី "32" នេះ អាចកើតមានឡើងបាន ដោយត្រូវការណ៍តំណែង នៃបំណោះ: ពោលគឺ "ម៉េ" គឺលោកគ្រូ សួន សេង បញ្ជាខ្ញុំឲ្យបញ្ចូនជំនួស ព្រោះ គេជឿជាក់ ខ្ញុំបានច្រើនជាអតីតមេ ក្នុងការដែលមិត្តហ៊ី អវត្តមាន។

ចំណារបន្ថែមនេះ ជាអក្សរខ្ញុំ និងអក្សរបង ម៉មណៃ។

ចំណារខ្ញុំ ខ្ញុំសរសេរតាមសេចក្តីសំរេចចិត្ត របស់ "ម៉េ"។ គាត់បញ្ជាឲ្យ ខ្ញុំអានឈ្មោះបន្តិចម្តងៗ ហើយគាត់សំរេចចិត្ត ខ្ញុំជាអ្នកកត់ត្រា។ ត្រឡប់ មកដល់ការិយាល័យ ខ្ញុំហៅបង ម៉ម ណៃ មកប្រគល់បញ្ជីដែល ខ្ញុំចារតាម បញ្ជា "ម៉េ" ឲ្យគាត់ ហើយគាត់ក៏ចារតាមទំរង់ការ របស់ខ្ញុំ ក្នុងការចារនេះ សំរាប់តែមួយពេលនេះផង។

បញ្ជាក់ ÷

1.- មិត្តហ៊ី អវត្តមានពីមន្ទីរ ស21 តាំងពីដើម។ គាត់មានបេសកកម្ម ទាក់ទងនឹងកងពលលេខ មួយចំនួន ទៅនៅតាមភូមិភាគ ជាមួយ "ម៉េ"។

2.- "ម៉េ" គឺលោកគ្រូ សួន សេង និង "ម៉េធី" គឺ នួន ជា បានបញ្ជា ខ្ញុំ បញ្ចូន ជំនួស ព្រោះ គេជឿជាក់ ខ្ញុំបានច្រើន ជា អតីតមេ ដែលតាមខ្ញុំចាំ គឺ បរលោក - លោកដុងក្រោយបំផុត គឺបញ្ជា ថ្ងៃ 2 ឬ ថ្ងៃ 3 មករា 1979 ដែលខ្ញុំបានរាយការណ៍រួចហើយ។

ថ្ងៃ 28 វិច្ឆិកា 2007

ឌុច

កាំង ហ្គេកអាវ ហៅឌុច

# សេចក្ដីបញ្ជាក់ បញ្ជី "31" – TSL 1866

ការបញ្ជូនជនរងគ្រោះទៅដើរដក ក្នុងសភាពការណ៍នៃកិច្ចដំណើរការប្រគល់ អាចចែកចេញជាពីរដំណាក់កាល ដូចដែលខ្ញុំបានរាយការណ៍ខាងមុខហើយ ។ ដំណាក់កាលទីមួយ គឺមិត្ត ហ៊ី ប្រើបងចំផែនការ ហើយគាត់ចែងបញ្ជូនចេញ ដោយមានការ ។ ដំណាក់កាលទីពីរ គឺបន្ទាប់ពីដាច់ចេញយ៉ាង សឺន សាន់ ហៅប្រេមក "មេ" គឺលោកគ្រូ សុន សេន បានបញ្ជាឱ្យមិត្ត ហ៊ី ស្នើយោបល់ខ្ញុំសិន ដើម្បីស្ទៀង កុំឱ្យដាច់ចេញយ៉ាង ។

បញ្ជី "31" នេះ ជាបញ្ជីក្នុងដំណាក់កាលទីពីរ ។

ចំណារបស់គាត់ (គឺមិត្ត ហ៊ី) លើបញ្ជីនេះ បញ្ជាក់ច្បាស់លាស់នូវឈ្មោះអ្នកដែលស្លាប់ មិនគាច់ចប់ ។

ក្នុងការអនុវត្តជាក់ស្ដែង គាត់ចាត់ក្រុមយកតែឈ្មោះអ្នកដែលស្លាប់ហើយ ទៅសើក្រដាសមួយសន្លឹក យកមកបង្ហាញខ្ញុំ ខ្ញុំបានចំណាំតាមតែបានស្លាប់ហើយដែរ ។

ថ្ងៃ 28 វិច្ឆិកា 2007

ឌុច

កាំង ហ្គេកអ៊ាវ ហៅ ឌុច

3 # សេចក្តីសារភាព

ខ្ញុំសូមសារភាពអំពីសំបុត្រមួយ ដែលកាលមុនខ្ញុំបដិសេធ។

សំបុត្រនោះ វាជាស្នាដៃមួយនៃប្រាជ្ញាផ្ទាល់របស់ខ្លួនខ្ញុំ ក្នុងការសួរចម្លើយ ម៉ែន សាន ហៅ យ៉ា។

នៅពេលដែលលោកចៅក្រម យូ ប៊ុនឡេង បង្ហាញភស្តុតាងនេះដំបូង ខ្ញុំបានតែបដិសេធ ដោយគោរពនូវ ចំណាប់ភ័យតក់ស្លុត គំនូសវៀន។ មូលហេតុ មកពីខ្ញុំនៅចាំថា ឱ្យសំណូមពរ របស់យើងខ្ញុំ ធ្លាក់មកដល់ការអនុវត្តជាក់ស្តែង គឺសំណូមពរ គាមគាំ ឱ្យបាន ច្បាប់ដើមចម្លើយនៃឯកសារ ជាភស្តុតាង មកអានពីចាំណា ដែលពិតជាត្រឹមត្រូវ។

ខ្ញុំសូមបញ្ជាក់ថា រឿងរ៉ាវទាំងអស់នៃជីវិតសន្តិបាលរបស់ខ្ញុំ ជាប្រវត្តិឧក្រិដ្ឋដ៏ឃោរឃៅបំផុត នឹកឃើញពេលណា ខ្លោចផ្សាពេលនោះ។ ខ្ញុំមិនដែលហ៊ាន ពិភាក្សារឿងនេះជាមួយនរណាទេ។ ហើយរឿងរ៉ាវទាំងអស់ ក៏កន្លងទៅលើស 29ឆ្នាំទៅហើយដែរ។ ម្ល៉ោះហើយ ខ្ញុំនៅចងចាំបានច្បាស់តែរឿងរ៉ាវមួយចំនួនប៉ុណ្ណោះ។

ម្យ៉ាងទៀត ខ្ញុំយកតែទំលាយដល់សក្ខីភាព ខ្ញុំចេះតែមានសរសៃប្រសាទម្នាក់ឯង គឺនៅដល់ការដែលអ្នកនយោបាយ លក់ដៃចាស់។

ស្នើរមក ខ្ញុំត្រូវការសក្ខីភាពគ្រប់បែបយ៉ាង ដើម្បីមេធាវីយោគ បំភ្លឺជូនតុលាការ នូវឧក្រិដ្ឋកម្ម ដែលកើតឡើងនៅមន្ទីរ ស21។

សំណូមពរ

ដោយច្បាប់ដើមចម្លើយនៃសក្ខីភាព ដែលគាត់មានវិធីការសួរចម្លើយ ម៉ែន សាន ហៅ យ៉ា ទាំងបីទំព័រនេះ ខ្ញុំបានចុះសញ្ញាសំគាល់ថា ក1, ក2 និងក3 សូមលោកចៅក្រមពិនិត្យ។ មេធាវីអន្តរជាតិខ្ញុំបានចុះសញ្ញាសំគាល់ថា ក4 លើសំបុត្រ ដែលខ្ញុំបានបដិសេធពីលើកមុន។

ថ្ងៃទី 28 វិច្ឆិកា 2007

[signatures]

កាំង ហ្គេកអ៊ាវ (ឌុច)

4 សេចក្ដីបញ្ជាក់លើឯកសារ ក1, ក2, ក3, ក4

ម៉ែន សាន ហៅ យ៉ា ជាបុគ្គលសំខាន់ម្នាក់ ដែលបក្សកុម្មុយនិស្តកម្ពុជាត្រូវការ ចម្លើយជាចាំបាច់ ម្ល៉ោះហើយ "មេ"គឺលោកស៊ុន សេន តាមដានការឆ្លើយចម្លើយជាប់ លាប់ណាស់ ទាំងតាមទូរលេខ ទាំងតាមការយកចម្លើយដែលមិនទាន់ស្អាតយកទៅមើល។ គាត់មានមតិពីរបីដង ជាបន្តបន្ទាប់។

យើងខ្ញុំទាំងពីរនាក់ គឺមិត្តប៉ុន និងខ្ញុំ ដើម្បីស្វែងរកការផ្ដើមក្បាលក្បត់ តែ ស្វែងរកមិនឃើញ ព្រោះមេជាអ្នកសំរេច។

ពាក្យ "បងឌុច" ដែលក្នុងសំបុត្រសរសេរ ម៉ែន សាន ហៅ យ៉ា គឺជាពាក្យ ដែលប្រើជំនួសពាក្យ "បងខ្មែរ" ដើម្បីស្វែងរកប្រតិកម្មប្រឆាំងរបស់ម៉ែន សាន ហៅ យ៉ា។ "មេ"ខ្ញុំជាអ្នកណែនាំបញ្ហានេះ។

ចំណែកលេខ IX សំគាល់ ម៉ែន សាន ហៅ យ៉ា លេខ VIII សំគាល់ កែវ មាស ជាលេខបន្ទប់ជាន់ បង្កើតការស្ដាប់ចម្លើយ ក៏មេណែនាំឲ្យ ប្រើដែរ។

ថ្ងៃ 28 វិច្ឆិកា 2007

[signature]

កាំង ហ្គេកអ៊ាវ ហៅឌុច

[signatures]